# គណៈកម្មការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេស

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា ៣៤ (ថ្មី) ចែងថា៖ *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។ បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។"*

បានឃើញច្បាប់បោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៧ វិសោធនកម្មឆ្នាំ ២០០៧ មាត្រា ៥០ (ថ្មី) ចែងថា៖ *"ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត ។ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម៖ មានសញ្ជាតិខ្មែរ; មានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត; មានទីលំនៅក្នុងឃុំសង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត; មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ; ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីអនុវត្តជាក់ស្តែងនូវវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។"*

បានឃើញអនុសាសន៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា លោកសាស្ត្រាចារ្យ សូរិយា សូបេឌី (Prof. Surya Subedy) ពាក់ព័ន្ធស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ ២០១២ និងការអនុវត្តន៍ឲ្យមានប្រសិទ្ធិភាពនូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១ ចែងថា៖ *"ដោយប្រជាពលរដ្ឋខ្មែរអាចកាន់សញ្ជាតិពីរ នោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរត្រូវអនុញ្ញាត ឲ្យប្រជាពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេស ជាពិសេសនៅតាមបណ្តាប្រទេសដែលមានស្ថានទូត និង/ឬស្ថានកុងស៊ុលរបស់ប្រទេសកម្ពុជា អាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន ដូចមានប្រទេសជាច្រើនបានធ្វើរួចមកហើយ ។"*

បានសង្កេតឃើញប្រជាពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេសជាអចិន្ត្រៃយ៍ជាង ៤៥០,០០០ នាក់ និងប្រជាពលករខ្មែរដែលធ្វើការនៅក្រៅប្រទេសជាង ៦០០,០០០ នាក់ បានផ្ញើប្រាក់ចូលប្រទេសកម្ពុជាប្រមាណជាង ៥០០ លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ៖

យើងខ្ញុំ ដែលជាម្ចាស់ហត្ថលេខាខាងក្រោម ស្នើសុំអង្គការសហប្រជាជាតិ គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ធ្វើការកែទម្រង់ការបោះឆ្នោតស៊ីជម្រៅ ដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្រៅប្រទេស មានសិទ្ធិចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន ទៅតាមការធានារបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

# COMMISSION for ELECTION RIGHT of OVERSEA CAMBODIANS (CEROC)

**Has seen the national constitution of Cambodia adopted in 1993, Article 34 (new) stated that:** *"Khmer citizens of both sexes shall enjoy the right to vote and to stand as candidates for the election. Khmer citizens of both sexes, at least eighteen years old, have the right to vote. Khmer citizens of both sexes, at least twenty-five years old, have the right to stand as candidates for the elections of the members of the National Assembly. Khmer citizens of both sexes, at least forty years old, have the right to stand as candidates for the elections of the members of the Senate. Provisions restricting the right to vote and the right to stand as candidates for the elections shall be determined by the Electoral Law."*

**Has seen the Electoral Law enacted in 1997, as amended in 2007, Article 50 (new) stated that**: **"***To be eligible to vote, every citizen must have his/her name in the voter lists and must have documents to certify his/her identity during the election. In order to have his/her name in the voter lists, every citizen must meet the following conditions:- Be a Khmer national; - Be eighteen (18) years or over on the polling day; - Have a residence in the Commune/Sangkat where he/she is going to cast his/her vote; - Not be in a situation of serving prison term; - Not be insane or under guardianship as certified by a competent ministry or institution. The National Election Committee must issue regulations and procedures in order to actually implement paragraph 1 of this Article."*

**Has seen the Recommendation of the Special Rapporteur of the United Nations on the situation of human rights in Cambodia, Prof. Surya Subedi in 2012, and the effective implementation of the Paris Peace Agreement in 1991, reported that:** *"Since Cambodia allows dual citizenship, the National Election Committee should make it possible for Cambodians living abroad to exercise their voting rights, at least in the countries where it has diplomatic and/or consular representation, as done by many other countries."*

**Has seen total remittances of more than 500 million US dollars per year pouring into Cambodia from approximate 450,000 Cambodians permanently living abroad and more than 600,000 Cambodians temporarily working abroad;**

We, undersigned, to request to the United Nations (UNs), the Cambodia National Rescue Party (CNRP), and the Cambodian People's Party (CPP), to conduct in-dept Election Reform by including Cambodians Overseas the right to vote to fully exercise their citizenship rights in accordance to the provision of the Cambodia national constitution and the Universal Declaration of Human Rights of the United Nations.

| No. | **First and Last Name** *(Please print)* | **Address** ***(#Home, City, State/Province, Country, Postal Code)*** | **Signature** |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

| **No.** | **First and Last Name** *(Please print)* | **Address** ***(#Home, City, State/Province, Country, Postal Code)*** | **Signature** |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |